ធ៧-០៧-១៣៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការត្រួតពិនិត្យស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

**ប្រការ ១**.-

ប្រកាសនេះមានគោលបំណង ដើម្បីបង្ការហានិភ័យនៃការប្តូរប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ២**.-

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យមួយចំនួនត្រូវបានកំណត់និយមន័យដូចខាងក្រោមៈ

- "ហានិភ័យនៃការប្តូរប្រាក់" គឺជាលទ្ធផលនៃការប្តូរប្រាក់ដែលមានលទ្ធភាពខាតបង់ខាងហិរញ្ញវត្ថុ ដែលកើតឡើងពីចលនាឡើងចុះនៃអត្រាប្តូរប្រាក់។
- "ហានិភ័យនៃការទូទាត់ការប្តូរប្រាក់" គឺជាលទ្ធផលនៃការប្តូរប្រាក់ដែលមានលទ្ធភាពខាតបង់ ដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយទូទាត់សងនូវរូបិយវត្ថុដែលខ្លួនបានលក់ តែអាចមិនទទួលមកវិញនូវរូបិយវត្ថុដែលខ្លួនបានទិញពីប្រតិបត្តិការប្តូរប្រាក់។
- "ស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណណាមួយ" ជាសមតុល្យសុទ្ធនៃរាល់ទ្រព្យសកម្ម ទ្រព្យអកម្ម និងខ្ទង់ក្រៅតារាងតុល្យការនៃរូបិយប័ណ្ណនោះ។ ស្ថានភាពចំហសុទ្ធក្នុងខ្ទង់ឥណយិកគឺជាស្ថានភាពវែង ។ ស្ថានភាពចំហសុទ្ធក្នុងខ្ទង់ឥណទាយី គឺជាស្ថានភាពខ្លី។

**ប្រការ ៣**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធភាពមួយដើម្បីកំណត់វាស់វែង តាមដាន និងត្រួតពិនិត្យនូវទំហំនិងប្រភពហានិភ័យនៃការប្តូរប្រាក់ និងហានិភ័យនៃការទូទាត់ការប្តូរប្រាក់ក្នុងកំឡុងពេលនៃថ្ងៃជួញដូរនិងនៅពេលបិទបញ្ជីប្រចាំថ្ងៃ។ លក្ខណៈនិងទំហំរបស់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះត្រូវស្របតាមទំហំនៃប្រតិបត្តិការប្តូរប្រាក់ និងស្ថានភាពប្តូរប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះ។

**ប្រការ ៤**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវរក្សាគ្រប់ពេល នូវស្ថានភាពចំហសុទ្ធជារូបិយប័ណ្ណណាមួយ ឬសរុបជារូបិយប័ណ្ណទាំងអស់ទោះក្នុងស្ថានភាពវែងឬខ្លីក៏ដោយមិនឱ្យលើសពី ២០ភាគរយនៃមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនោះឡើយ។

**ប្រការ ៥**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវផ្ញើជូនធនាគារជាតិនៃកម្ពុជានូវរបាយការណ៍ប្រចាំខែ ទាំងហាដកូពី (Hard copy) និងសូហ្វកូពី (Soft copy) ស្តីពីស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណឱ្យបានទៀងទាត់តាមគំរូក្នុង ឧបសម្ព័ន្ធភ្ជាប់ជាមួយ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវធានាផងដែរថាស្ថានភាពរូបិយប័ណ្ណត្រូវបានរាយការណ៍ត្រឹមត្រូវមកធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦**.-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះនឹងត្រូវរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៧**.-

បទបញ្ញាលេខធ៧-៩៥-០១ បបជ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៥ ស្តីពី ការត្រួតពិនិត្យស្ថានភាពរូបិយប័ណ្ណចំហសុទ្ធរបស់ធនាគារពាណិជ្ជនិងរាល់លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជា និរាករណ៍។

**ប្រការ ៨.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩**.-

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

## តារាង ឧបសម្ព័ន្ធ

## ការគណនាស្ថានភាពចំហសុទ្ធនៃរូបិយប័ណ្ណ

## Net Open Position

**ឈ្មោះធនាគារ............**

Bank's Name

អត្រាប្តូរប្រាក់ ១ដុល្លារ (Exchange Rate 1USD) =

នាកាលបរិច្ឆេទ...................................

មូលនិធិផ្ទាល់សុទ្ធគិតជាលានរៀល (Bank's Net Worth)

As at………………………..

គិតជាលានរៀល In Million KHR

| រូបិយប័ណ្ណ<br>Currency | ខ្ទង់ផ្សេងៗបន្ទាប់ពីដកចេញសវិធានធន<br>Elements after deduction of affected provision | | | | ស្ថានភាពរូបិយប័ណ្ណចំហសុទ្ធ<br>Net Open Position | រូបិយប័ណ្ណចំហសុទ្ធ/ មូលនិធិផ្ទាល់សុទ្ធ (%)<br>Net Open Position / Net Worth (%) | កំរិតកំណត់ (%)<br>Limit (%) | ភាពលើស (១)<br>Excess (1) |
|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ៥ | | | |
| | ទ្រព្យសកម្ម<br>Assets | ទ្រព្យអកម្ម និងមូលធន<br>Liabilities and Capital | រូបិយប័ណ្ណត្រូវទទួល<br>Currencies Receivable | រូបិយប័ណ្ណត្រូវចំណាយ<br>Currencies Payable | + (វែង) ឬ - (ខ្លី)<br>+(Long) or -(Short) | | | |
| | + | - | ខ្ទង់ក្រៅតារាងតុល្យការ +<br>Off Balance Sheet + | ខ្ទង់ក្រៅតារាងតុល្យការ -<br>Off Balance Sheet - | (១ + ២ + ៣ + ៤)<br>(1+2+3+4) | | | |
| USD | | | | | | | 20% | |
| KHR | | | | | | | 20% | |
| EUR | | | | | | | 20% | |
| SGD | | | | | | | 20% | |
| HKD | | | | | | | 20% | |
| THB | | | | | | | 20% | |
| JPY | | | | | | | 20% | |
| VND | | | | | | | 20% | |
| srb (Grand Total) | | | | | | | | |
| | (២) | (៣) | | | (៤) | | | |

(១) នៅពេលដែលមានភាពលើស គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវពន្យល់ជាលាយលក្ខណ៍អក្សរពីមូលហេតុនិងវិធានការកែសំរួល

(1) Where there is an excess, the bank shall submit a written explanation of the origin of each excess, and the measures taken to remedy the situation.

(២) ចំនួនសរុបទ្រព្យសកម្មក្នុងតារាងតុល្យការ

(2) Total equal to total assets on the balance sheet

(៣) ចំនួនសរុបទ្រព្យអកម្ម និងមូលធនក្នុងតារាងតុល្យការ

(3) Total equal to total liabilities on the balance sheet

(៤) ចំនួនសរុប = សូន្យ

(4) Total = Zero

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ

**នាយក**

**Bank's Manager**

**អ្នកធ្វើតារាង**

**Prepared By**